**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៣៥៧៥ ព.ណ..ភ៧

ថ្ងៃ អង្គារ ៨រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ពាណិជ្ជករ អាជីវករ និង សាធារណជនទូទៅឲ្យបានជ្រាបថា៖ គណៈកម្មការរៀបចំពិព័រណ៍ The 6th Food & Beverage Trade Fair នៃខេត្ត អយុធ្យា ព្រះរាជាណាចក្រថៃ នឹងរៀបចំកម្មវិធីពិព័រណ៍ "The 6th Food & Beverage Trade Fair" ដែលនឹងប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ ០២ ខែធ្នូ ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលតាំងពិព័រណ៍ The Hall Convention, Ayutthaya City Park នាខេត្តអយុធ្យា ព្រះរាជាណាចក្រថៃ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញពាណិជ្ជករ អាជីវករ ដែលជាម្ចាស់ក្រុមហ៊ុន និងសហគ្រាសទាំងអស់ ដែលមានបំណងទៅចូលរួមផ្សព្វផ្សាយពីផលិតផលរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្ម ក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ សូមមកទាក់ទង និងបំពេញបែបបទនៅនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ត្រឹមថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយភ្ជាប់មកជាមួយនូវពាក្យស្នើសុំចូលរួម និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទីពីរ នៃអគារទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១៧ ៩៦០ ២០០ ឬ ០១២ ៦០០ ៧៧៨ ឬ ០១២ ៧៧៧ ៩៥៩

អាសយដ្ឋានអ៊ីម៉ែល៖ chousetha@gmail.com ឬ veasna_mao@yahoo.com ឬcheaputhea@yahoo.com

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

**KINGDOM OF CAMBODIA**

**Nation - Religion - King**

**Ministry of Commerce**

N°3575MOC(D)/EA

Phnom Penh, 02 October, 2018

**ANNOUNCEMENT**

The Ministry of Commerce of the Kingdom of Cambodia has the honor to inform the Traders and Business people that The 6th Food & Beverage Trade Fair Committee of AYUTTHAYA, Kingdom of Thailand will organize **"The 6th Food & Beverage Trade Fair"**, which will be held from November 29th to December 02nd, 2018 at the Hall Convention, Ayutthaya City Park, Ayutthaya, Kingdom of Thailand.

In this regard, the Ministry of Commerce has the honor to invite all the owner of Companies and Enterprises who wish to advertise their products or to look for trading partners in this event, please kindly contact and register at Department of Exhibition Affairs of the General Directorate of Trade Promotion, Ministry of Commerce by filling in application form and other related documents by 16th November, 2018 at the latest stage.

For other detailed information related to participation in the above-mentioned exhibitions, please kindly contact: Department of Exhibition Affairs, General Directorate of Trade Promotion, Lot No. 19-61, Russian Federation Blvd, Phum Toek Thla, Sangkat Toek Thla, Khan Sen Sok, Phnom Penh, or Via the following:

Tel: 017 960 200 / 012 600 778 / 012 777 959

E-mail: chousetha@gmail.com/cheaputhea@yahoo.com/veasna_mao@yahoo.com

THANK YOU!